# កំណត់បដិមាសាស្ត្រខ្មែរ ៖ ឈុតពីរកន្លែងទាក់ទងនឹងនាវាចរ*

Mireille Bénisti
*Centre National de la Recherche Scientifique*

ខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងទៅលើហោជាងពីរ គឺនៅប្រាសាទព្រះខ័នមួយ និងមួយទៀតនៅប្រាសាទតាកែវ។ មូលហេតុមកអំពីហោជាងទាំងពីរបង្ហាញពីតួអង្គរូបរាងធំម្នាក់ឈរនៅលើនាវាក្នុងលំនាំតែមួយ។ ហោជាងនោះពុំដូចគ្នាបេះបិទទេ តែចំណុចដែលស្រដៀងគ្នាគួរឲ្យប្រៀបធៀបនោះមានច្រើន។ ឧទាហរណ៍ ៖ ឥរិយាបទព្រមទាំងទំហំធំជាងគេនៃតួអង្គដែលពោលខាងលើ, រូបរាងនាវាជាដើមនោះ ធ្វើឲ្យខ្ញុំគិតថារូបទាំងពីរប្រហែលជាទាក់ទងនឹងរឿងតែមួយ។ គឺរឿងជាប្រភពរូបនោះហើយ ដែលខ្ញុំស្នើយកមកសិក្សាទីនេះ។

ហោជាងនៅប្រាសាទព្រះខ័ន (រូប ១ក និង ១ខ) បង្ហាញពីនាវាមួយមានរាងជាសត្វទឹក ក្បាលជាក្បាលសត្វល្មូន ឬក្បាលនាគ។ មនុស្សកំពស់កំពធំលើសគេម្នាក់ ឈរងាកក្បាលមកក្រោយ រីឯដៃក៏សន្ធឹងមកក្រោយដែរ។ បុរសនោះអមសងខាងទៅដោយមនុស្សពីរនាក់ទៀត ដែលទំហំមាឌតូចជាងច្រើន។ នៅក្រោមនាវាគេឃើញមានត្រី។ នៅពីមុខក្បាលនាវា, ខាងឆ្វេង, មានមនុស្សអង្គុយលុតជង្គង់, ដៃផ្គុំប្រណម្យ។ នៅលើមកទៀត មានមនុស្ស



រូប ១ក - ប្រាសាទព្រះខ័ន ៖ ហោជាង (រូបដើមរបស់អ្នកនិពន្ធ)



រូប ១ខ - ប្រាសាទព្រះខ័ន ៖ ហោជាង (ស្ថានភាពបច្ចុប្បន្ន)

* ឈ្មោះអត្ថបទដើមគឺ "Notes d'iconographie khmère. I. Deux scènes nautiques", *BEFEO* LI, 1963, p.95-98, Pl.I-II, ប្រែសម្រួលជាភាសាខ្មែរនៅទីនេះដោយ អាំង ជូលាន។ ដោយសាររូបថតក្នុងអត្ថបទដើមពុំសូវច្បាស់ យើងសូមបង្ហាញរូបថតថ្មីជាជំនួយ (រូប ១ខ និង ២ខ) ថ្វីត្បិតតែវត្ថុខ្លះមានភាពទ្រុតទ្រោមជាងមុន។

តូចៗពីរនាក់ ម្នាក់នោះកាន់វត្ថុអ្វីមួយមានរាងដូចត្រីសូល៏។ ក្រៅអំពីនេះមានវត្ថុផ្សេងៗដាក់បញ្ឈររាងដូចប៉ៃល[១] ហើយមានរបនាក្បូរក្បាច់មើលទៅសមជាច្រវ៉ានិងចង្កូត។

ហោជាងនៅតាន៉ៃ (រូប ២ក និង ២១) ធំជាងនោះបន្តិច ហើយនៅមាំទាំជាង។ គេឃើញរូបនាវារាងជាសត្វទឹក, ក្បាលជាសត្វល្មូនឬនាគដូចគ្នា



រូប ២ក- ប្រាសាទតាន៉ៃ ៖
ហោជាង,តួប៉មកណ្តាល,ផ្នែកខាងជើង



រូប ២១- ហោជាងដដែល ថតសាជាថ្មី

[១] កំណត់អ្នកប្រែ ៖ មើលតាមភ្នែកខ្មែរ ឃើញរូបនេះរាងផ្លិតប្រភេទ "ចាមរ"។

ដែរ។ ប៉ុន្តែនៅទីនេះ កន្សៀទូកមានរាងជាកន្ទុយត្រី។ បុរសម្នាក់មានទំហំលើសគេឯងដែលនៅជុំវិញ ឈរនៅលើទូកនោះ។ ក្បាលគាត់ងាកក្រោយរីឯដៃក៏សន្ធឹងមកជាមួយគ្នាដែរ។ មនុស្សបួននាក់កំពុងអុំទូកយ៉ាងសកម្ម។ ដើម្បីបង្ហាញថាទីនោះជាទឹក គេច្លាក់រូបរលកព្រមទាំងរូបត្រី។ ខាងឆ្វេងនិងខាងស្តាំមានដើមឈើនិងសត្វផ្សេងៗ ដែលបញ្ជាក់ថាជាដីគោក ព្រោះនៅទីនោះមានមនុស្សម្នាក់លុតជង្គង់លើកដៃប្រណម្យ។ ឯលើអាកាសវិញគេឃើញមានទេពនិករហោះនៅពីលើជុំវិញតួអង្គនោះផង ដៃកាន់ក្លោះព្រមទាំងទង់ផ្សេងៗ។

តើវិចិត្រករខ្មែរជំនាន់នោះចង់បង្ហាញអំពីរឿងអ្វី?

ដូចយើងដឹងស្រាប់ ព្រះខ័ននិងតានៃស្ថិតនៅក្នុង "រចនាបថបាយ័ន្ត" ហើយសំណង់សាសនាពេលនោះច្រើនតែឧទ្ទិសទៅព្រះលោកេស្វរ ដែលជាពោធិសត្វប្រកបដោយករុណាធម៌ "ជួយបញ្ចៀសមនុស្សឲ្យផុតពីគ្រោះភ្លើង, ទឹកជំនន់, លិចនាវានៅក្នុងជលសា, ចោរប្លន់, គុកច្រវ៉ាក់ជាដើម"[២]។ រូបលោកេស្វរមានច្លាក់នៅច្រើនកន្លែងណាស់ ឧទាហរណ៍នៅក្នុងស្រះប្រាសាទនាគព័ន្ធ គេបង្ហាញព្រះអង្គកាឡាជាតួសត្វសេះឈ្មោះ "ពលាហ" កំពុងស្រោចស្រង់ក្រុមមនុស្សដែលជិតលិចលង់ទឹក ហើយដែលតោងលើខ្លួនព្រះអង្គជាប់[៣]។

បើមើលតែចំណុចប៉ុន្មាននេះ យើងអាចគិតថារូបនៅហោជាងទាំងពីរប្រហែលជារូបលោកេស្វរ ដែលជាទេពសង្គ្រោះលោកទេឬអ្វី? ប៉ុន្តែបើត្បិតតែតួអង្គនោះធំជាងគេគួរឲ្យយល់ដូច្នេះ ក៏គង់មានចំណុចផ្សេងទៀតដែលពុំអាចស្របគ្នាបាន ដូចជាប្រការដែលពុំឃើញមានរូបព្រះពុទ្ធអមិតាភនៅមុខក្នុងសក់សោះ[៤]។

ហេតុនេះតើហោជាងនៅព្រះខ័ននិងតានៃនិយាយអំពីរឿងអ្វី?

ដោយសង្កេតឃើញថា មានទំនាក់ទំនងគ្នារវាងសិល្បៈខ្មែរនិងភូមាដែរ ខ្ញុំក៏ល្បងធ្វើការរុករកក្នុងសិល្បៈភូមា ក្រែងរកការបំភ្លឺអ្វីមួយបាន។

គេដឹងថា នៅលើសំណង់សាសនាខ្លះនៃភូមា[៥] តែងមានផ្ទាំងចម្លាក់ខ្លះដែលសាងឡើងនៅចន្លោះស.វ.ទី១១ និងស.វ.ទី១៤ (សូមកុំភ្លេចថារចនាបថបាយ័ន្តស្ថិតនៅស.វ.ទី១២ ពោលគឺក្នុងជំនាន់នោះ) ហើយដែលនិទានអំពីអតីតជាតិនៃព្រះពុទ្ធអង្គ។ ផ្ទាំងនិមួយៗតែងមានចារឈ្មោះជាតកនៅពីក្រោម។ ផ្ទាំងមួយនោះមានចម្លាក់ប្លែក ដែលធ្វើឲ្យខ្ញុំនឹកមកហោជាងទាំងពីរ។ គេច្លាក់នៅលើចេតិយ៍ឈ្មោះ "មង្គលចេតិយ៍" (Mańgalacheti)[៦] នៅបុរាណដ្ឋាន Pagan។ លើនោះមានរូបនាវាមួយផ្ទុកមនុស្សបីនាក់ (រូបលេខ ៣)។ ម្នាក់នោះកំពុងអុំឬក៏កាន់ចង្កូតនាវាដែលបរកាត់ទឹក សម្គាល់



រូបលេខ ៣ - ផ្ទាំងចម្លាក់នៅមង្គលចេតិយ៍ នាក្រុងPagan

[២] កំណត់អ្នកនិពន្ធ ៖ L.Finot, "Lokeçvara en Indochine", in *Etudes Asiatiques,* vol. XIX, p.229.
[៣] កំណត់អ្នកនិពន្ធ ៖ *Ibid*, p.249.
[៤] កំណត់អ្នកប្រែ ៖ ធម្មតា នៅលើរូបព្រះលោកេស្វរ មានរូបព្រះអង្គតូចមួយអង្គុយសមាធិ ព្រះនាមហៅថា "អមិតាភ" ហើយដែលគេច្លាក់នៅលើក្លួងសក់ខាងមុខ។
[៥] កំណត់អ្នកនិពន្ធ ៖ Duroiselle, "Pictorial representations of Jâtaka", in *Annual Report of the Archaeological Survey of India,* 1912-1913, p.87.
[៦] កំណត់អ្នកនិពន្ធ ៖ *Ibid*, p.109, pl. LVI, 39.

បានដោយមានរូបរលកនិងហង្សត្រី។ នាវានោះចាកចេញពីច្រាំងដែលមានដើមឈើមួយដើមព្រមទាំងមនុស្សម្នាក់។ អក្សរដែលចារិកក្រោមនោះបង្ហាញថា នេះជារឿង "សមុទ្ទវាណិជជាតក ៤៦៦" ។

បើតាមជាតកនោះ[៣] គឺព្រះពោធិសត្វបានយោនយកកំណើតជាជាងឈើ នៅភូមិជាងឈើមួយជិតក្រុងពារាណសី ហើយត្រូវបោះបង់ចោលស្រុកជាមួយប្រជាជនចំនួនមួយពាន់គ្រួ។ ទាំងអស់គ្នាក៏ខ្ចាត់ព្រាត់មកជាប់លើកោះមួយ ដែលមានម្រេញគង្វាល[៨] រស់នៅ។ ក្រុមម្រេញគង្វាលក៏ប៉ុនប៉ងនិងពិឃាតអ្នកដំណើរទាំងនោះឲ្យផុតពូជ។ កាលនោះគ្រួសារចំនួនប្រាំរយស្ថិតនៅក្រោមការគ្រប់គ្រងនៃព្រះពោធិសត្វ រីឯប្រាំរយគ្រួទៀតជាចំណុះជាងឈើម្នាក់ ដែលជាមនុស្សខ្លៅ។ អ្នកទាំងពីរត្រូវបានទេពមួយអង្គមកប្រាប់ឲ្យដឹងពីគម្រោងម្រេញគង្វាល ដោយទូន្មានឲ្យនាំគ្នាលួចរត់ចេញពីទីនោះទៅ។ ព្រះពោធិសត្វក៏ធ្វើតាមឱវាទនោះ ហើយនាំគ្រួសារទាំងប្រាំរយចេញផុតតាមនាវាមួយ ចំណែកឯជាងឈើល្ងង់ខ្លៅនោះ រវល់តែស្ដាយស្រណោះធម្មជាតិកោះជាទីត្រកាល ក៏ត្រូវស្លាប់ព្រមដោយអ្នកស្រុកទាំងប្រាំរយគ្រួនោះ។

វិចិត្រករនៅ Pagan ច្លាក់រឿងនេះដោយសង្ខេបជាទីបំផុត។ គេឃើញព្រះពោធិសត្វកាន់ច្រវាអុំទូកចេញពីកោះ។ នៅមុខព្រះអង្គ មានមនុស្សស្រីម្នាក់និងប្រុសម្នាក់នៅសងខាងបង្គោលឬដងអ្វីមួយ ហើយដែលតាងឲ្យអ្នកស្រុកទាំងប្រាំរយគ្រួ។ នៅឯច្រាំងវិញ គេឃើញទេពនិករដែលបានទូន្មានសង្គ្រោះនោះនៅលើមែកឈើមួយ។

មើលមកទល់ត្រឹមនេះ ឃើញថាផ្ទាំងចម្លាក់ភូមាព្រមទាំងហោជាងនៅព្រះខ័ននិងតានៃ មានចំណុចប្រហាក់ប្រហែលគ្នា។ ប៉ុន្តែបើពិនិត្យឲ្យបានល្អិតជាងនេះទៅទៀត ឃើញថាពុំមែននិទានរឿងតែមួយដូចគ្នាឡើយ។ នៅលើផ្ទាំងភូមាតួអង្គទាំងអស់មានទំហំប៉ុនៗគ្នា ចំណែកឯលើហោជាងខ្មែរវិញ តួអង្គនៅកណ្ដាលធំជាងអ្នកឯទៀតឆ្ងាយ។ នាវានៅលើផ្ទាំងភូមា ក៏ពុំមានរាងជាមច្ឆាជាតិឬក៏ក្បាលជានាគដែរ។ ម្យ៉ាងទៀតចម្លាក់ហោជាងទាំងពីរពុំបង្ហាញថានៅមាត់ច្រាំងមានតួអង្គណានៅលើមែកឈើឡើយ។

សេចក្ដីសន្និដ្ឋានរបស់ខ្ញុំគឺហោជាងនៅព្រះខ័ននិងតានៃពុំនិទានអំពី "សមុទ្ទវាណិជជាតក"ទេ។ តែទោះជាដូច្នោះក្ដី តើអាចជារឿងជាតកណាមួយផ្សេងទៀតឬទេ? ខ្ញុំជឿខ្លួនឯងថាបានរកឃើញហើយនូវជាតកដែលពាក់ព័ន្ធនិងរូបទាំងពីរ ពោលគឺ "សីលានិសង្សជាតក"[៩] ដែលពន្យល់ពីផលអនិសង្សហូរចូលមកតាមការប្រតិបត្តិធម៌។

រឿងនោះតំណាលថា កាលសម័យព្រះពុទ្ធកស្សប[១០] មានសាវ:មួយអង្គ ព្រមដោយជាងកាត់សក់ម្នាក់ជិះសំពៅធ្វើដំណើរ ហើយសំពៅនោះក៏លិចធ្លាយ។ អ្នកទាំងពីរតោងបន្ទះក្ដារមួយជាប់ ក៏បណ្ដែតខ្លួនមកដល់កោះមួយ។ ជាងកាត់សក់ពិឃាតសត្វស្លាបមួយចំនួនបម្រុងនិងបរិភោគ។ ពេលនោះសាវ:ជញ្ជឹងគិតថា[១១] ៖ "នៅទីនេះ ក្រៅពីជម្រកទាំងបី គ្មានអ្វីទៀតឡើយដែលអាចនាំសត្វលោកដល់ត្រើយសុខ។ គិតដូច្នោះហើយក៏ផ្ចង់ស្មារតីត្របាញ់តែលើព្រះត្រៃរត្ន័" ពោលគឺព្រះពុទ្ធ, ព្រះធម៌និងព្រះសង្ឃ។ "ពេលដែលអារម្មណ៍សាវ:ផ្ដោតជាប់នឹងគំនិតនោះ ស្ដេចនាគដែលមានកំណើតនៅកោះនោះក៏កាឡាខ្លួនជានាវាមួយយ៉ាងធំ ដែលមានទេពសមុទ្រមួយអង្គជាអ្នកអូសទាញមក"។ បន្ទាប់មក មានការរៀបរាប់អំពីនាវាអស្ចារ្យនោះ។ "ទេពសមុទ្រស្រែកសួរថា ៖ មានអ្នកដំណើរណាត្រូវទៅជម្ពូទ្វីបឬទេ?"[១២]។ ពេលនោះ សាវ:មិនត្រឹមតែបានឡើងនាវានោះរួចខ្លួនឯងប៉ុណ្ណោះទេ តែដោយអនិសង្សដែលបានមកពីធ្វើធម៌ គឺថែមទាំងអាចឧទ្ទិសផលឲ្យជាងកាត់សក់នោះចេញរួចជាមួយគ្នាមកដល់ក្រុងពារាណសីផង។ ក្រោយពីបានជួយសង្គ្រោះអ្នកទាំងពីរហើយ "ទេពសមុទ្រក៏ទៅសម្ដែងធម៌ទេសនាពីលើអាកាសមក រួចទើបវិលថ្កានមកលំនៅវិញ ដោយនាំទាំងស្ដេចនាគមកវិញផង"។ ដូចនៅក្នុងជាតកដទៃទៀតដែរ គឺព្រះពុទ្ធសក្យមុនី ដែលគេជឿថាជាអ្នកនិទានរឿងនោះ ព្រមទាំងបញ្ជាប់មកត្រង់ចំណុចសរជាតិ ៖ "បុរសលុះដោយធម៌នោះ ក្រោយមកក៏រលត់ខន្ធផុតវដ្ដសង្សារទៅ។ ឯស្ដេចនាគយោនយកកំណើតមកជាព្រះសារីបុត្រ រីឯទេពសមុទ្រនោះគឺតថាគតនេះឯង"។

---

[៣] កំណត់អ្នកនិពន្ធ ៖ នៅក្នុងបញ្ជីរបស់លោក Fausböll ជាតកនេះលេខ៤៦៦។ លោក Duroiselle មើលចំណងជើងនោះថា ៖ Samundapaniya jat-pe-tak-smā, 466 .

[៨] ពាក្យអ្នកនិពន្ធជាបារាំងថា lutins ពោលគឺជាអមនុស្សដែលមានរូបរាងដូចមនុស្សដែរ តែល្អិតតូច រស់នៅជាក្រុមក្នុងព្រៃ។ នៅទីនេះ ខ្ញុំសូមប្រើពាក្យថា "ម្រេញគង្វាល" ដើម្បីជាការងាយស្ដាប់តែប៉ុណ្ណោះ ។

[៩] តាមបញ្ជីរបស់លោក Fausböll ជាតកនេះលេខ១៩០។

[១០] កំណត់អ្នកប្រែ ៖ ព្រះពុទ្ធអង្គទី៣ បន្ទាប់ពីព្រះកុកសន្ធនិងព្រះនាគមនោ។ សព្វថ្ងៃយើងរស់នៅក្នុងព្រះសាសនាទី៤ គឺព្រះសមណគោតម។ តំណទៅមុខ គឺព្រះស្រីអារ្យមេត្រីយ៍។

[១១] កំណត់អ្នកនិពន្ធ ៖ ពាក្យពេជន៍ដែលខ្ញុំដាក់ចន្លោះអកន្តរគឺជាពាក្យប្រែពីជាតកបាលី ដោយអ្នកស្រី Ginette Martini ។

[១២] កំណត់អ្នកនិពន្ធ ៖ ជម្ពូទីបជាឈ្មោះប្រទេសឥណ្ឌា (សំស្ក្រិត ៖ ជម្ពូទ្វីប) ។

ឥឡូវនេះចូរយើងពិនិត្យហោជាងទាំងពីរ ជាពិសេសហោជាងប្រាសាទតាកែវ ដែលរក្សានៅបានល្អពុំសូវរិចរិល។ យើងឃើញថាមាននាវាមួយមានក្បាលនិងកន្ទុយជាសត្វទឹក សមជានាគកាឡាខ្លួនក្នុងជាតកខាងលើ។ នៅលើនាវា តួអង្គកណ្ដាលជាទេពសមុទ្រ (គឺព្រះពុទ្ធអង្គក្នុងជាតិជាពោធិសត្វនោះ)។ ទំហំខ្លួនធំខុសគេនោះ គឺត្រូវនឹងភាពជាទេព (បើនៅលើផ្ទាំងចម្លាក់ភូមាវិញ ព្រះពោធិសត្វដែលកាលនោះជាជាងឈើសាមញ្ញ ពោលគឺមិនមែនជាទេព មានរូបរាងមិនខុសអ្វីពីអ្នកឯទៀតឡើយ)។ ម្យ៉ាងទៀត គេមានឆ្លាក់រូបទេពនិករតូចៗ ហោះហើរកាន់ភ្លោះ ព្រមទាំងរូបទេពប្រណម្យជុំវិញនោះផង។ ចំណែកឯកោះវិញ គឺគេឆ្លាក់ឲ្យមានសត្វនិងរុក្ខជាតិជាទីសម្គាល់ ដូចជាសមុទ្រជុំវិញនោះដែរ ដែលគេឆ្លាក់សម្គាល់ដោយរូបរលកនិងត្រី។ តួអង្គទេពនោះ បែមុខព្រមទាំងសន្ធឹងដៃទៅរកក្បាលនាវាដែលមានអ្នកអុំបួននាក់។ ទីនេះអាចសន្មត់ថា នៅត្រង់ឈុតដែលទេពនោះស្រែកសួរថា “មានអ្នកដំណើរណាត្រូវទៅជម្ពូទ្វីបឬទេ ?”។

នៅលើហោជាងប្រាសាទព្រះខ័នវិញក៏មាននាវា មានតួអង្គកណ្ដាលធំលើសគេដូចគ្នា និងអ្នកប្រណម្យដូចគ្នាដែរ។ ប៉ុន្តែនៅលើដីវិញឃើញមានមនុស្សលុតជង្គង់ ឯនៅលើនាវាគឺជាជនរងគ្រោះដែលបានរួចរស់ជីវិតនៅជុំវិញតួអង្គធំ។ តួអង្គនេះលើកដៃចង្អុល ហើយសម្លឹងទៅជើងមេឃរំលងលើក្បាលនាវានោះទៀត។ យើងអាចសន្មត់ថា ទីនេះគឺត្រង់ពេលដែលនាវាមកដល់ត្រើយទ្វីបវិញ ព្រោះឃើញអ្នកអុំលើកច្រវានិងចង្កូតឡើងលើដើម្បីចុះចត។

ខ្ញុំយល់ថា ហេតុផលដែលលើកមកនេះ សមល្មមនឹងឲ្យជឿថា ហោជាងនៅព្រះខ័ននិងតាកែវត្រូវបានជាងចម្លាក់ខ្មែរនៅស.វ.ទី១២ និទានបង្ហាញរឿងជាតក ពោលឲ្យច្បាស់ជាងនេះទៀត គឺឈុតពីរកន្លែងនៃសីលានិសង្សជាតក។

មានហោជាងពីរផ្សេងទៀតនៅប្រាសាទតាកែវ ដែលគេជឿថាបង្ហាញពីរឿងជាតកដែរ។ មួយនោះ[១៣] មានរូបក្មេងពីរនាក់ហើយប្រហែលជាសម្រង់រឿងព្រះវេស្សន្តរជាតក[១៤] ដែលនៅក្នុងចំណោមរឿងទសជាតកដ៏ល្បីល្បាញ។ មួយទៀត[១៥] មានតួអង្គមួយអង្គុយ ដៃកាន់ជញ្ជីង ហើយប្រហែលជារឿង “សិពិជាតក”[១៦]។

គួរឲ្យចាប់អារម្មណ៍ណាស់អំពីចម្លាក់រឿងជាតកទាំងនេះនៅលើប្រាសាទខ្លះនៃ “របនាបថបាយ័ន្ត” ព្រោះអាចផ្ដល់ជាតម្រុយក្នុងការប្រៀបធៀបរកអាយុកាលនៃប្រាសាទ ឬផ្នែកខ្លះនៃប្រាសាទក្រុមនោះ។ ម្យ៉ាងទៀត ចម្លាក់ទាំងនេះអាចជួយបំភ្លឺខ្លះៗអំពីបញ្ហាពុទ្ធសាសនាហីនយាន និងមហាយាននៅស្រុកខ្មែរនាសតវត្សទី១២។

---

[១៣] កំណត់អ្នកនិពន្ធ ៖ មានរូបថតនៅសារមន្ទីរ Guimet, លេខ ៣១១៦៩៤ / ១៦។
[១៤] កំណត់អ្នកនិពន្ធ ៖ ជាតកលេខ៥៤៧។
[១៥] កំណត់អ្នកនិពន្ធ ៖ មានរូបថតនៅសារមន្ទីរ Guimet, លេខ ៣១១៦៩៤ / ១៩។
[១៦] កំណត់អ្នកនិពន្ធ ៖ ចំពោះជាតកនេះ សូមអាន A. Foucher, *Les vies antérieures du Buddha*, Paris 1955, p.324 et 325, note 1